FAIR LABOR ASSOCIATION

## IX – ដំណើរការបណ្តឹងភាគីទី ៣

គោលបំណងនៃដំណើរការបណ្តឹងភាគីទី៣ គឺ ដើម្បីស៊ើបអង្កេតតាមការចោទប្រកាន់ពីបទល្មើសដែលកើតមានជារឿយៗ រឺ ហេតុការណ៍ល្មើសច្បាប់ធ្ងន់ធ្ងរដែលបានកើតឡើងលើបុគ្គលណាម្នាក់ ដោយយោងទៅតាមក្បួនច្បាប់នៅកន្លែងការងារ រឺ គោលការណ៍ត្រួតពិនិត្យនៅក្នុងសេវាកម្មនៃក្រុមហ៊ុនដែលចូលរួមជាមួយនឹងសមាគមពលកម្មមិនលំអៀង ព្រមទាំងនៅក្នុងស្ថាបន័មហាវិទ្យាល័យ និង សាកលវិទ្យាល័យ ដែលចូលរួមនៅក្នុងកម្មវិធីត្រួតពិនិត្យរបស់សមាគមពលកម្មមិនលំអៀង (ទាំងអស់សំដៅថាជា "សហការី " នៅក្នុងផ្នែកនៃធម្មនុញ្ញនេះ)។ ផ្នែកគន្លឹះនៃដំណើរការនេះ គឺជា ការកែបំបាត់នូវអ្វីដែលពាក្យបណ្តឹងបញ្ជាក់ពីបទល្មើសច្បាប់តាមសកម្មភាពកែតម្រូវ។

### ក /បែបបទនៃការប្តឹងតវ៉ា :

**ជំហានទី១:** ការដាក់ពាក្យបណ្តឹង

ភាគីណាក៏ដោយអាចដាក់ពាក្យបណ្តឹងភាគីទី៣ ទៅនាយកប្រតិបត្តិសមាគមពលកម្មមិនលំអៀង ទាក់ទងទៅនឹងរោងចក្រ លើកលែងតែភាគីនោះជាអ្នកចុះត្រួតពិនិត្យទទួលស្គាល់ដោយ សមាគមពលកម្មមិនលំអៀង ហើយដែលត្រូវបានចាត់អោយចុះទៅធ្វើការងារ នៅរោងចក្រនោះ ក្នុងកំឡុងពេល ៦ ខែ គិតមកត្រឹមពេលដាក់ពាក្យបណ្តឹង ។ បុគ្គលិកសមាគមពលកម្មមិនលំអៀង នឹងពិគ្រោះជាមួយម្ចាស់បណ្តឹងដើម្បីវាយតំលៃជាជំហានដំបូង ថាតើត្រូវជំរុញដំណើរបណ្តឹងទៅមុខទៀត រឺ យ៉ាងណា ។ ភាគីដើមចោទត្រូវមានភស្តុតាង រឺ ពតិមានជាក់លាក់ច្បាស់លាស់មួយចំនួន និងដែលអាចយកជាការបាន ថាបទល្មើសបានកើតឡើង ហើយក្នុងការវាយតំលៃនេះ សមាគមពលកម្មមិនលំអៀង នឹងពិចារណាលើសច្ចភាពនៃបណ្តឹងមុនៗដែលបានធ្វើឡើងដោយភាគីទី ៣។ បើសេចក្តីសំរេចថាត្រូវជំរុញទៅមុខនោះ ដំណើរការបណ្តឹងនឹងឈានទៅជំហានទី ២, តែបើ សេចក្តីសំរេចថាមិនត្រូវជំរុញទៅមុខ នោះនាយកប្រតិបត្តិ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយពន្យល់ពីមូលហេតុនៃ ការបញ្ឈប់ដំណើរការបណ្តឹង។ អ្នកដាក់ពាក្យបណ្តឹងអាចស្នើសុំ រឺ មិនស្នើសុំ

Fair Labor Association 1505 22nd Street, NW Washington, DC 20037
Telephone 202-898-1000 Fax 202-898-9050

ទៅសមាគមពលកម្មមិនលំអៀងអោយលាក់អត្តសញ្ញាណរបស់ខ្លួន។ បើម្ចាស់បណ្តឹងសំរេចអោយធ្វើបណ្តឹងជាសាធារណៈនោះនាយកប្រតិបត្តិអាចប្រកាសទទួលអត្តសញ្ញាណនៃបណ្តឹងជាសាធារណៈ។

**ជំហានទី២ :** ការជូនដំណឹងទៅក្រុមហ៊ុន

នាយកប្រតិបត្តិនឹងជូនដំណឹងទៅក្រុមហ៊ុនដែលត្រូវបានគេប្តឹង ព្រមទាំងផ្តល់ទៅក្រុមហ៊ុននោះនូវពតិមានដែលបានផ្តល់ដោយអ្នកដើមចោទ។ សមាគមពលកម្មមិនលំអៀងក៏នឹងផ្តល់ផងដែរនូវការចង្អុលបង្ហាញជាបឋមពីការមិនប្រព្រឹត្តតាមគោលការណ៏ការងារ ។ នៅពេលនោះក្រុមហ៊ុនមានពេលវេលាចំនួន ៤៥ ថ្ងៃដើម្បីស្នើសុំអោយដំណើរការឈានចូលទៅជំហានទី ៣ រឺ ដើម្បីស៊ើបអង្កេតផ្ទៃក្នុងពីភាពមិនប្រព្រឹត្តតាមច្បាប់ដែលត្រូវបានចោទប្រកាន់។ ប្រសិនបើក្រុមហ៊ុនជ្រើសយកធ្វើការវាយតំលៃដោយខ្លួនឯង នោះត្រូវរាយការណ៍ជាលាយលក្ខណ៍ អក្សរទៅនាយកប្រតិបត្តិអោយបានមុនពេលបញ្ចប់កាលកំណត់នៃរយៈពេល ៤៥ ថ្ងៃនេះ ថាតើមាន បទល្មើស មែនរឺទេ។ បើមានមែននោះតើត្រូវបានដោះស្រាយនិងកែប្រែយ៉ាងដូចម្តេច។ បើសមាគមពលកម្មមិនលំអៀងយល់ស្របតាមការវាយតំលៃរបស់ក្រុមហ៊ុននោះ អ្នកដើមចោទ នឹង ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ក្នុងករណីភាគីដើមចោទមិនអាចផ្តល់នូវពតិមានដែលនាំ អោយសេចក្តីសន្និដ្ឋាននោះក្លាយជាចំណោទ នោះនាយកប្រតិបត្តិនឹងបញ្ចប់ដំណើរការបណ្តឹង ហើយ នឹងផ្តល់នូវរបាយការណ៍សង្ខេបទៅភាគីក្រុមហ៊ុន និង អ្នកដើមចោទ។ បើដំណើរការបណ្តឹង មិនត្រូវបានបញ្ចប់នៅដំណាក់កាលនេះទេ នោះវានឹងឈានចូលទៅជំហានទី ៣។

ក្នុងកំលុងពេលនេះប្រសិនបើនៅពេលណាមួយ រឺ នៅដំណាក់កាលពីមួយទៅមួយ នាយកប្រតិបត្តិរកឃើញសកម្មភាពដែលត្រូវធ្វើជាបន្ទាន់ (ឧទាហរណ៍ដូចជា ថាតើមានការសងសឹកតបទៅកម្មករ រឺ ថាតើកម្មករ រឺ / និង អ្នកគ្រប់គ្រង ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ពីភាពអន្តរាយដែលនឹងកើតមានជាបន្ទាន់) នោះសមាគមពលកម្មមិនលំអៀងរក្សាសិទ្ធិ ក្នុងការចាត់វិធានការណ៍ ក្នុងហេតុផលនិងរក្សានូវធម្មនុញ្ញសមាគមពលកម្មមិនលំអៀង។ អាស្រ័យទៅតាមភាពតឹងតែងនៃស្ថានការណ៍ ប៉ុន្តែមិនដាក់កំហិតទេ សកម្មភាពនោះ អាចមានមួយក្នុងចំណោមវិធានការណ៍ដូចតទៅ : សុំអោយក្រុមហ៊ុនអោយធ្វើអន្តរាគមន៏, បញ្ជូនអ្នកសង្កេតការណ៍ទៅកាន់កន្លែងកើតហេតុ, សុំអោយរដ្ឋអំណាចជួយធ្វើអន្តរាគមន៏ ។ សម្មភាពបែបនេះ នឹងត្រូវបានពិនិត្យឡើងវិញតាមការព្រមព្រៀងពីគណៈកម្មការប្រតិបត្តិនៃក្រុមប្រឹក្សាសមាគមពលកម្មមិនលំអៀង។

**ជំហានទី ៣:** ការវាយតំលៃពាក្យបណ្តឹងដោយសមាគមពលកម្មមិនលំអៀង

សមាគមពលកម្មមិនលំអៀងនឹងសំរេច ថាតើត្រូវបន្ត រឺ មិនបន្តដំណើរការវាយតំលៃនាពេលអនាគតដោយប្រើអ្នកជំនាញការ រឺ អ្នកត្រួតពិនិត្យឯករាជ្យពីខាងក្រៅ។ បើសេចក្តីសំរេចថាមិនបន្តទេនោះ

នាយកប្រតិបត្តិ នឹងបញ្ចប់ដំណើរការ ហើយនឹងផ្តល់របាយការណ៍សង្ខេបជូនទៅភាគីដើមចោទ និង ភាគីក្រុមហ៊ុន។ បើការសំរេចថាត្រូវបន្ត នោះការវាយតំលៃនឹងត្រូវធ្វើឡើង។ ក្រុមហ៊ុននឹងត្រូវធានាថាអ្នកវាយតំលៃបានចូលទៅគ្រប់កន្លែង និង មានឱកាសពេញលេញដើម្បីប្រមូលពត៌មាន ដែលអ្នកវាយតំលៃគិតថាជាការចាំបាច់។ អ្នកវាយតំលៃនឹងសំរេចកិច្ចការនេះតាមវិធីរហ័ស ដែលអាចយកជាការបានយោងទៅតាមការណែនាំសំរាប់វាយតំលៃនៃសមាគមពលកម្មមិនលំអៀង។ អ្នកវាយតំលៃនឹងរៀបចំជារបាយការណ៍មួយរៀបរាប់ពីកិច្ចការ និង អ្វីដែលខ្លួនបានរកឃើញ។

ក្រុមហ៊ុននឹងបង់ថ្លៃទាំងស្រុងជូនមកសមាគមពលកម្មមិនលំអៀងសំរាប់ដំណើរការវាយតំលៃ ប៉ុន្តែអាចបង់ត្រឹមមួយចំនួន រឺ គ្រប់ការចំនាយលើការត្រួតពិនិត្យឯករាជ្យពីខាងក្រៅ, នេះអាស្រ័យលើការសំរេចចិត្តរបស់សមាគមពលកម្មមិនលំអៀងតែប៉ុណ្ណោះ។

ក្នុងករណីក្រុមហ៊ុនបដិសេធមិនអោយចូលត្រួតពិនិត្យនោះ នាយកប្រតិបត្តិនឹងបញ្ចប់ក្តី ហើយចេញរបាយការណ៍សង្ខេបជូនទៅអ្នកដើមក្តី ក្រុមហ៊ុន និង ក្រុមប្រឹក្សានាយកសមាគមពលកម្មមិនលំអៀងដោយរៀបរាប់ពីការសំរេចចិត្តរបស់ក្រុមហ៊ុន។

**ជំហានទី ៤** : ការកែប្រែកំហុស

បើសិនអ្នកវាយតំលៃរកឃើញនូវសភាវៈសំខាន់ៗស្តីពីភាពល្មើសច្បាប់ដូចដែលត្រូវបានចោទប្រកាន់ក្នុងពាក្យបណ្តឹងខាងដើម នោះក្រុមហ៊ុននឹងធ្វើការជាមួយសមាគមពលកម្មមិនលំអៀងដើម្បីបង្កើតនូវគម្រោងសមស្របមួយកែប្រែកំហុស និង ប្រតិបត្តិតាមគំរោងដើម្បីបំពេញចិត្តសមាគមពលកម្មមិនលំអៀង។ ប្រសិនបើក្រុមហ៊ុនបរាជ័យក្នុងការអនុវត្តនិនោះ នាយកប្រតិបត្តិនឹងបញ្ចប់ដំណើរការ ហើយជូនដំណឹងទៅអ្នកដើមចោទ ក្រុមហ៊ុន និង ក្រុមប្រឹក្សានាយកតាមរយៈរបាយការណ៍សង្ខេប។ បើក្រុមហ៊ុនយល់ព្រមតាមដំណើរការកែប្រែកំហុស នៅពេលនោះគេនឹងផ្តល់នូវពង្រាងគំរោងកែប្រែកំហុសក្នុងរយៈពេល ៣០ ថ្ងៃ។ សមាគមពលកម្មមិនលំអៀង នឹងរៀបចំតារាងតាមដានគំរូមួយស្តីអំពីព្រឹត្តការណ៍នោះ ព្រមទាំងការទទួលយកការវាយតំលៃដោយនាយកប្រតិបត្តិ ហើយផ្សព្វផ្សាយលើគេហទំព័ររបស់ខ្លួនរយៈពេល ៩០ ថ្ងៃ។ ការកែប្រែកំហុសដែលបានធ្វើឡើង រឺ កំពុងដំណើរការធ្វើនឹងត្រូវបានបញ្ចូលទៅក្នុងតារាងតាមដាន។ សមាគមពលកម្មមិនលំអៀង នឹងរៀបចំរបាយករណ៍សង្ខេបនៃបណ្តឹង និង ការវិវឌ្ឍនិមកទល់បច្ចុប្បន្ន នឹងផ្តល់របាយការណ៍នោះជូនទៅ ភាគីដើមចោទភាគីក្រុមហ៊ុន និង ក្រុមប្រឹក្សានាយកសមាគមពលកម្មមិនលំអៀង។ របាយការណ៍នេះនឹងរួមបញ្ចូលទាំងពត៌មានដែលបានផ្តល់ជូនរួចមកហើយនៅក្នុងតារាងតាមដាន ហើយក៏អាចរួមបញ្ចូលនូវពត៌មានបន្ថែមស្តីពីដំណើរការដែលកំពុងប្រព្រិត្តទៅ។ របាយការណ៍នឹងបញ្ជាក់ពីបទល្មើស (ជាក់ស្តែង រឺ ទំនងជាមាន) ដូចដែលបានចោទប្រកាន់នៅក្នុងបណ្តឹង ហើយដែលបានកែបំបាត់កំហុសដើម្បីបំពេញ

ចិត្តសមាគមពលកម្មមិនលំអៀង។ បើពុំទាន់បានកែប្រែទេនោះ របាយការណ៍នឹងបញ្ជាក់ថាដំណើរការ "កែប្រែកំពុងប្រព្រឹត្តទៅ " នោះមានន័យថា ការបំពេញចិត្តសមាគមពលកម្មមិនលំអៀងកំពុងតែ វិវឌ្ឍនិទៅមុខ។ ក្នុងករណី ការកែប្រែកំហុសកំពុងប្រព្រឹត្តទៅនោះ សមាគមពលកម្មមិនលំអៀងនឹងបន្តរាយការណ៍ ជូនទៅភាគីដើមចោទ និង ភាគីក្រុមហ៊ុន រហូតដល់ពេលមួយដែលសមាគមពលកម្មមិនលំអៀង សម្រេចថា ការកែប្រែកំហុសបានសំរេចដល់កំរិតពេញលេញមួយ រឺ ការកែប្រែកំហុស នោះមានទំនងនឹងបានសំរេចហើយ។ នៅក្នុងខណៈនោះ សមាគមពលកម្មមិនលំអៀងនឹងធ្វើរបាយការណ៍សង្ខេបបញ្ចប់មួយ ហើយជូនទៅ ភាគីដើមចោទ ភាគីក្រុមហ៊ុន និង ក្រុមប្រឹក្សានាយកសមាគមពលកម្មមិនលំអៀង ។

ចំពោះស្ថាប័នមហាវិទ្យាល័យ និង សាកលវិទ្យាល័យដែលចូលរួម របាយការណ៍សង្ខេបនេះនឹងត្រូវបានបញ្ជូនទៅតាមសាលាផងដែរ យោងទៅតាមធម្មនុញ្ញនៃសមាគមពលកម្មមិនលំអៀង។

## ខ /<u>សេចក្តីប្រកាសជាសាធារណៈដែលធ្វើឡើងដោយភាគីនិមួយៗ</u> :

តាមឧត្តមគតិ ដំណើរការបណ្តឹងភាគីទី៣ គួរកើតឡើងក្នុងបរិបទរួចផុតពីការចោទប្រកាន់ និងការនិយាយបញ្ឆិតបញ្ឆៀងជាសាធារណៈ។ ចាប់ពីជំហានទី២មក ភាគីនិមួយៗ អាចនិយាយជាសាធារណៈថាបណ្តឹងត្រូវបានធ្វើឡើងដើម្បីតវ៉ាក្រុមហ៊ុនចំឈ្មោះមួយ ហើយកំពុងស្ថិតនៅជំហានទី...នៃ ដំណើរការបណ្តឹងភាគីទី៣។ បើក្រុមហ៊ុន រឺ ភាគីបណ្តឹងជ្រើសយកការប្រកាសជាសាធារណៈចំពោះ សាច់រឿងនៃពាក្យបណ្តឹង បន្ទាប់មកតាមការវិនិច្ឆ័យ នាយកប្រតិបត្តិអាចបង្ហាញពតិមានដែលមានការកែតំរូវនូវការយល់ឃើញខុសពីស្ថានការណ៍ក្នុងករណីធ្ងន់ធ្ងរ នាយកប្រតិបត្តិអាចស្វែងរកអោយឃើញថាសេចក្តីប្រកាសដោយភាគីក្រុមហ៊ុនបញ្ចូលទាំងបទល្មើសនឹងកម្មវិធីសមាគមពលកម្មមិនលំអៀង រឺ បើការប្រកាសជាសាធារណៈដោយភាគីដើមចោទ នាយកប្រតិបត្តិអាចនឹងផ្តល់នូវហេតុផលសំខាន់ៗនៃការបញ្ឈប់បណ្តឹង។

## គ /<u>បណ្តឹងដែលទាក់ទងទៅនឹងស្ថាប័នមហាវិទ្យាល័យ រឺ សាកលវិទ្យាល័យ</u>:

ដោយការគោរពទៅនឹងដំណើរការបណ្តឹងភាគីទី៣ ខាងដើម ក្នុងកណើបណ្តឹងទាក់ទងទៅនឹង:

សេវាកម្មនៃស្ថាប័នមហាវិទ្យាល័យ រឺ សាកលវិទ្យាល័យ ប្រភេទក, សេវាកម្មនៃស្ថាប័នវិទ្យាល័យ រឺសាកលវិទ្យាល័យ ប្រភេទខ ដែលធ្វើ រឺ បង្កើតផលិតផលក្រោមអាជ្ញាប័ណ្ណពីសាខាមហាវិទ្យាល័យ រឺ សាកលវិទ្យាល័យ រឺក៏ សេវាកម្ម មួយដែលបានកាន់កាប់ និង ប្រតិបត្តិ ដោយស្ថាប័នវិទ្យាល័យ រឺ សាកលវិទ្យាល័យប្រភេទគ នាយកប្រតិបត្តិ នឹងចាត់និតិវិធីក្នុងលក្ខណៈស្រដៀងគ្នា នឹងពិភាក្សាព្រមទាំងសម្របសម្រួលជាទៀងទាត់ជាមួយនឹងសម្ព័ន្ធ សាកលវិទ្យាល័យនៅក្នុងការវាយតំលៃពីភាពដែលអាចទុកចិត្តបាននៃពាក្យបណ្តឹង

ពីបទល្មើសនោះ និង បើ ពាក្យបណ្តឹងសមស្របតាមខ្នាតគំរូ ក្នុងការវាយតំលៃនៃស្ថាប័នវិទ្យាល័យ រឺ សាកលវិទ្យាល័យគឺជាការឆ្លើយតបទៅនឹងបទល្មើសដែលត្រូវបានចោទប្រកាន់ ។

បន្ថែមពីលើនេះស្ថាប័នមហាវិទ្យាល័យនិងសាកលវិទ្យាល័យនឹងត្រូវបានជូនដំណឹងពីបណ្តឹងភាគីទី៣ ដែលជាប់ទាក់ទងនឹងអ្នកម៉ៅការបន្ត និង អ្នកផ្គត់ផ្គង់នៃស្ថាប័នប្រភេទគ រឺ ឃ ។